អង្គរបុរី
សម្លេងខ្មែរនៅបរទេស

# ការវិភាគ

## របស់ព្រះតេជព្រះគុណ ហុក-សាវណ្ណ
## ក្រោមប្រធានបទ រាជរដ្ឋាភិបាលបង្ក្រាបអ្នកនេសាទខ្មែរខុសច្បាប់នៅបឹងទន្លេសាប ប៉ុន្តែមិនបង្ក្រាបទូកយួនតាំងទីលំនៅខុសច្បាប់នៅបឹងទន្លេសាបឡើយ ។

www.hoksavann.org
ថ្ងៃទី២៣ មករា ២០១២



តាមពត៌មានជាបន្តបន្ទាប់មកថា រាជរដ្ឋាភិបាលខ្មែរបាននិងកំពុងបង្ក្រាបអ្នកនេសាទខ្មែរនៅបឹងទន្លេសាប ដោយអូសយកមងអួនផ្តស់ដែលដាក់តាមដងទន្លេសាបមកកំទេចនិងដុតចោល ។ ការបង្ក្រាបនេះមានជាច្រើនលើក ប៉ុន្តែនៅតែមានប្រព្រឹត្តបំពាននៅឡើយ ។ យើងយល់ថា អ្នកប្រព្រឹត្តនោះពុំមែនជាប្រជាពលរដ្ឋតូចតាចទេ គឺមានអ្នកធំអ្នកមានអំណាចនៅពីក្រោយ ។ បើរាជរដ្ឋាភិបាលចង់បំបាត់រឿងនេះមែន ត្រូវតែអង្កេតតាមចាប់អ្នកនៅពីក្រោយ ជាពិសេសតាមដានពិនិត្យមើលអ្នកទទួលខុសត្រូវខាងជលផលនេះ ក្រែងត្រូវនឹងសុភាសិតខ្មែរថា «មាន់ណានៅក្នុងជង្រុកស្រូវ មាន់នោះហើយដែលស៊ីស្រូវនោះ» ។ វិធានការរបស់រាជរដ្ឋាភិបាលចាត់ការទៅលើអ្នកនេសាទខុសច្បាប់ ហាក់ដូចជាត្រឹមត្រូវមួយផ្នែកហើយ ប៉ុន្តែត្រង់យួនដែលតាំងទីលំនៅលើផ្ទៃទឹកទន្លេសាប រាជរដ្ឋាភិបាលខ្មែរគ្មានចាត់ការអ្វីសោះ ។

តាមពត៌មានថា តាមបណ្តោយបឹងទន្លេសាបក្នុងខេត្ត៤គឺ ខេត្តសៀមរាប, កំពង់ធំ, កំពង់ឆ្នាំង និងបាត់ដំបង សហគមន៍យួនបានតាំងទីលំនៅលើទូកក្នុងផ្ទៃទឹកទន្លេសាបចំនួនប្រហែល៥០ម៉ឺនទូក ។ មានហាងលក់ទំនិញ សាលារៀនយួន វត្តយួន ភោជនីយដ្ឋាន ក្លឹបកំសាន្ត មន្ទីរសន្តិសុខ មានរហូតដល់ស្ថានីយ៍ចាក់សាំងផង ។ ជាពិសេសសហគមន៍យួននៅលើទូកច្រើនជាងគេគឺ នៅឆ្នុកទ្រូខេត្តកំពង់ឆ្នាំង ។ នៅឆ្នុកទ្រូនេះហើយ ដែលអភិបាលខេត្តខ្មែរខេត្តកំពង់ឆ្នាំង បានធ្វើដំណើរទៅឯអគ្គរដ្ឋទូតយួននៅភ្នំពេញ សុំឲ្យសហគមន៍យួនមករស់នៅលើគោកវិញ ដោយអាជ្ញាធរសុខចិត្តផ្តល់ឲ្យដីពីរហិកតា និងប្រាក់១ម៉ឺនដុល្លារក្នុងយួនមួយគ្រួសារ ។ តែសំណើរនេះហាក់ដូចជាស្ងាត់បាត់ឈឹង គ្មានលេចឮអ្វីឡើយ ។ នៅកំពង់លួង ខេត្តពោធិសាត់ ក៏មានយួននៅលើទូករាប់ម៉ឺនទូក ។ នៅព្រែកក្រា និងព្រែកទល់ខេត្តបាត់ដំបង មានផ្ទះយួនធំៗជាច្រើន ដោយយកឈើធ្វើជាគ្រឹះក្នុងទឹក ឯកន្លែងដទៃទៀត គេបុកឫស្សីធ្វើជាគ្រឹះ ឬដាក់ធុងសាំងពីក្រោមហើយសង់ផ្ទះពីលើ ។ អ្នកខ្លះនៅលើទូកតែម្តង ដោយទូកធំទូកតូច មានចលនាចុះឡើងលក់ឥវ៉ាន់ហាក់ដូចជានៅលើគោក ។ សហគមន៍យួនទាំងនោះបានថវិកាជួយឧបត្ថម្ភពីសហគមន៍យួននៅបរទេស និងពីរដ្ឋាភិបាលយួននៅប្រទេសយួន ។

ខ្មែរមិនប្រកាន់ជាតិសាសន៍ទេ ចំពោះយួនទាំងនោះមកកម្ពុជាត្រូវច្បាប់ឬមិនត្រូវច្បាប់ វាជារឿងមួយដែលរាជរដ្ឋាភិបាលត្រូវដោះស្រាយ ប៉ុន្តែពលរដ្ឋខ្មែរមានការងឿងឆ្ងល់ថា ហេតុអ្វីបានជារាជរដ្ឋាភិបាលខ្មែរ បណ្តោយឲ្យសហគមន៍យួនទាំងនោះតាំងទីនៅក្នុងផ្ទៃទឹកទន្លេសាប មិនចាត់ការឲ្យសហគមន៍យួនទាំងនោះមករស់នៅលើគោក ។ ការរស់នៅក្នុងទឹកនាំឲ្យខូចបរិស្ថាន ធ្វើឲ្យទឹកក្រខ្វក់ ដែលជាលំនៅមច្ឆជាតិ ។ បឹងទន្លេសាបជាតំបន់ទេសចរណ៍មួយផ្នែក ដែលអ្នកទេសចរជិះនាវាទស្សនាកំសាន្តមើលទេសភាពតាមដងទន្លេ ។ ការតាំងលំនៅក្នុងទឹកធ្វើឲ្យក្រខ្វក់ដោយការបន្ទោរបង់មូត្រលាមក និងចោលកាកសំណល់ និងសំរាមផ្សេងៗ ។ នៅក្នុងពិភពលោកកម្រមានប្រទេសឲ្យប្រជាពលរដ្ឋតាំងទីនៅក្នុងទឹក វៀរលែងតែទីនោះគ្មានដីគោកសោះ ។

រាជរដ្ឋាភិបាលខ្មែរមិនបង្ក្រាបជនជាតិយួន ដែលតាំងទីលំនៅក្នុងទឹកទន្លេសាប តែបែរបង្ក្រាបជនជាតិរបស់ខ្លួននៅលើដីគោក ដូចជានៅបឹងកក់នៃរាជធានីភ្នំពេញជាដើម ឲ្យរងទុក្ខវេទនាដោយពុំមានសំណងត្រឹមត្រូវ ។ ប្រជាពលរដ្ឋត្រូវគេដេញពីលំនៅដ្ឋានមានច្រើនកន្លែង ក្រុមប្រដាប់អាវុធរួមជាមួយក្រុមហ៊ុន បានប្រើអំពើហិង្សាទៅលើប្រជាជន ដោយគ្រាន់តែពលរដ្ឋការពារដីនិងលំនៅដ្ឋានរបស់ខ្លួន ។ អាជ្ញាធរបានប្រើដំបងឆក់ រហូតដល់ប្រើកាំភ្លើងបាញ់ប្រជាពលរដ្ឋរបស់ខ្លួនឲ្យត្រូវរបួសទៀតផង ។ នេះជាការរំលោភសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិត្រង់មាត្រា៥ដែលចែងថា «គ្មានជនណាម្នាក់ត្រូវទទួលទារុណកម្មឬការធ្វើបាបយ៉ាងសាហាវឃោរឃៅអមនុស្សធម៌ឬយ៉ាងថោកទាបឡើយ»។និងរំលោភមាត្រា១២ដែលចែងថា «គ្មានបុគ្គលណាត្រូវគេជ្រៀតជ្រែក ដោយរំលោភក្នុងកិច្ចការផ្ទាល់ខ្លួន លំនៅដ្ឋានគ្រួសារ សំបុត្រឆ្លើយឆ្លង ឬត្រូវគេប៉ះពាល់ដល់កិត្តិយស និងកេរ្តិ៍ឈ្មោះរបស់ខ្លួនបានឡើយ ។ បុគ្គលគ្រប់រូបមានសិទ្ធិនិងមានច្បាប់ការពារខ្លួន ប្រឆាំងនឹងការជ្រៀតជ្រែក ឬការប៉ះពាល់ទាំងនោះ» ។ កំហុសនេះអាចប្តឹងទៅតុលាការអន្តរជាតិបាន ។

យើងបន្តអត្ថបទនេះ ដោយទទួលដំណឹងមួយដ៏ឃោរឃៅគួរឲ្យរន្ធត់នៅខេត្តក្រចេះ ។ កាលពីថ្ងៃទី១៨ មករា ២០១២ ទាហានការពារក្រុមហ៊ុនដំណាំកៅស៊ូ TTY បានបាញ់រះទៅលើប្រជាពលរដ្ឋនៅភូមិ២ធ្នូ ស្រុកស្នួល ខេត្តក្រចេះ ដែលការពារដីចំការរបស់ខ្លួន ។ អំពើសាហាវឃោរឃៅព្រៃផ្សៃនោះ បណ្តាលឲ្យប្រជាពលរដ្ឋរងរបួស៤នាក់ ។ គេសង្កេតឃើញរូបភាពតាមសារពត៌មាន ទាហានពីរនាក់ឈរលើដំបូលឡាន ទាញកាំភ្លើងបាញ់តម្រង់ទៅលើប្រជាពលរដ្ឋស្លូតត្រង់ ដែលគ្មានអាវុធក្នុងដៃ ដូចគេបាញ់សត្វ ។ តើការបាញ់នោះ ទាហានពីរនាក់នោះសំរេចបាញ់ដោយខ្លួនឯង ឬដោយមេក្រុមហ៊ុនឈ្មោះឧក-ញ៉ាអាន-ម៉ារ៉ឌីប្រាប់ឲ្យបាញ់ កាលណាប្រជាពលរដ្ឋប្រឆាំងនឹងការឈូសឆាយដី ឬដោយអ្នកមានសមត្ថកិច្ចនៅពីក្រោយ ? ប្រជាពលរដ្ឋបានដករបាំងដែលបិទផ្លូវលេខ 76A ក្រោយពេលដែលអាជ្ញាធរខេត្តក្រចេះ បានសន្យាជាមួយប្រជាពលរដ្ឋថា

ឲ្យក្រុមហ៊ុនប្រគល់ដីឲ្យប្រជាពលរដ្ឋវិញ  តាមចាប់អ្នកដែលបានបាញ់  ឲ្យក្រុមហ៊ុនចេញតម្លៃព្យាបាលរបួសដែលទាហានបាញ់ ឲ្យក្រុមហ៊ុនបញ្ឈប់ការឈូសឆាយដី ដើម្បីទុកពេលដោះស្រាយ ។

យើងយកពត៌មាននេះមកចុះផ្សាយបន្ត មកអំពីរន្ធត់ខ្លាំង ដោយទាហានប្រើអំពើហិង្សា បាញ់ប្រជាពលរដ្ឋស្លូតត្រង់ដែលការពារដីស្រែចំការរបស់ខ្លួន ។ ខ្មែរបានឆ្លងកាត់អំពើព្រៃផ្សៃគួរឲ្យរន្ធត់ជាច្រើន  ហើយពេលនេះគួរតែបញ្ឈប់កុំឲ្យកើតមានតទៅទៀត ។ ទាហានស៊ីឈ្នួលដែលការពារក្រុមហ៊ុន ចូរអ្នកគិតថា គ្រាប់កាំភ្លើងដែលអ្នកបាញ់ចូលក្នុងសាច់គេ តើធ្វើឲ្យគេឈឺចុកចាប់យ៉ាងណា ? មុននឹងឲ្យក្រុមហ៊ុនឈូសឆាយ ត្រូវតែដោះស្រាយជាមួយប្រជាពលរដ្ឋ ឲ្យស្រុះស្រួលគ្នាជាមុនសិន ។ បើរាជរដ្ឋាភិបាលមិនចូលដៃជាមួយជនឧក្រិដ្ឋនោះទេ ត្រូវតែបញ្ឈប់កុំឲ្យអ្នកការពារក្រុមហ៊ុនកាន់អាវុធ ហើយព្រមានកុំឲ្យប្រើអំពើហិង្សាទៅលើប្រជាពលរដ្ឋ ដែលប្រឆាំងនឹងការឈូសឆាយដី ។ ដោយប្រជាពលរដ្ឋខ្មែរអស់ជំនឿនឹងតុលាការខ្មែរដូច្នេះមានតែប្តឹងអ្នកប្រព្រឹត្តឧក្រិដ្ឋកម្មទៅតុលាការអន្តរជាតិ ។៚

*          *

*